ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

អគ្គលេខាធិការដ្ឋាន

លេខ: ៦៥ /២០១៥ អ.កបធ.សជណ

# សេចក្តីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា **នៅថ្ងៃអង្គារ ទី០១ ខែធ្នូ ឆ្នាំ២០១៥** នៅទីស្តីការក្រុមប្រឹក្សាធម្មនុញ្ញ អគារ " **ស** " នៃវិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ មានបើកកិច្ចប្រជុំពេញអង្គ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យ និង សម្រេច លើសំណើលេខ ៦៨២ រ.ស ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

កិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចជាឯកច្ឆន្ទចេញសេចក្តីសម្រេច លេខ ១៥៨/០០៦/២០១៥ កបធ.ច ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន ។

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh,ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ